# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ តើការប្រព្រឹត្តរបស់ធាន-វុទ្ធី នៅទួលរាជា ជាសកម្មភាពលើកដំកើងព្រះពុទ្ធសាសនា ឬបំផ្លាញព្រះពុទ្ធសាសនា ?

website ៖ www.hoksavann.org

*ថ្ងៃទី១២ សីហា ២០០៩*



*យើងជាខ្មែរគោរពព្រះពុទ្ធសាសនា ទាំងបព្វជិតទាំងគ្រហស្ថ ចង់ឲ្យការប្រតិបត្តិព្រះពុទ្ធសាសនាត្រឹមត្រូវតាមព្រះពុទ្ធដីកា អដ្ឋកថាដីកា ជាលក្ខណៈព្រះពុទ្ធសាសនាថេរវាទ ដែលធ្វើតាមព្រះថេរៈជាព្រះអរហន្ត ធ្វើសង្គាយនា មិនកែប្រែធម៌វិន័យ ព្រះពុទ្ធសំដែងយ៉ាងណារក្សាទុកយ៉ាងនោះ ។ ក្នុងសម្បត្តិឧបាសក ឧបាសិកា ៥ខមានខមួយពោលថា ឧបាសក ឧបាសិកាមិនត្រូវជឿមង្គលភ្ញាក់ផ្អើលឡើយ ។ ជឿមង្គលភ្ញាក់ផ្អើលដូចជាជឿថា ព្រះផុសហើយមានអ្នកមានបុណ្យកើតឡើងហើយជាដើម ។ នៅប្រទេសកម្ពុជា ជនពាលបានប្រឌិតរឿងមិនពិតជាច្រើនថាជាពុទ្ធសាសនា ដើម្បីបញ្ឆោតពុទ្ធសាសនិកជនខ្មែរឲ្យជឿ ដើម្បីលាភសក្ការៈប្រាក់កាស ។ បណ្តាអបិយជំនឿទាំងនោះ មានអបិយជំនឿខ្លះបានសាបសូន្យហើយ ចំណែកអបិយជំនឿដែលបង្កើតឡើងដោយធាន-វុទ្ធី កំពុងតែមានដំណើរឆ្ពោះទៅរកការសាបសូន្យដែរ ដោយពុទ្ធសាសនិកជនដែលជឿដឹងការពិតអំពីការបោកបញ្ឆោត ។ ការបោកបញ្ឆោតរបស់ធាន-វុទ្ធី គឺយកព្រះពុទ្ធរូបទៅកប់ ហើយទៅថតថាព្រះផុស តាំងខ្លួនជាសម្តេចជួន-ណាតចាប់ជាតិ តាំងខ្លួនជាព្រះសិរអារ្យមេត្រី តាំងខ្លួនជាព្រះសម-*

ណគោត្តម ដោយមានព្រះនាងគង់-ស៊ីអ៊ីម (រឿងគេតែងនៅហុងកុង) ជាសាវកហែហាម ។ កុហកថា បួងដែលកសាងសំណង់នៅទូលរាជា គឺធ្វើនៅឋានព្រះឥន្ទ ត្រៃចីវរកឋិន ព្រះឥន្ទបានយកទៅក្រាលគ្រងនៅឋានលើ តែតាមពិតយកមកលក់នៅផ្សារទីក្រុងភ្នំពេញ ឲ្យគេឃោសនាធ្វើបុណ្យកឋិន បុណ្យផ្កា គាត់យកភាគរយ គាត់ជាគ្រហស្ថតែបំបួសព្រះសង្ឃ អង្គុយលើព្រះសង្ឃ ឲ្យព្រះសង្ឃថ្វាយបង្គំគាត់ មានរូបភាពអង្គុយលើផ្កាឈូក មានពពករសាត់ជុំវិញ គឺធ្វើជារូបគាត់ហោះ ។

បន្ទាប់ពីមន្ត្រីសង្ឃទៅគំរាមធាន-វុទ្ធីឲ្យឈប់ធ្វើសកម្មភាពដែលខុសធម៌វិន័យទាំងអស់ មានការបំបួសជាដើម ឥឡូវនេះធាន-វុទ្ធីឈប់បំបួសព្រះសង្ឃដែលស្លៀកពាក់លឿងទៀតហើយ តែនៅតែបំបួសដោយឲ្យស្លៀកសពាក់សវិញ ។ មួយទៀត ធាន-វុទ្ធីបានពោលតិះដៀលមើលងាយព្រះសង្ឃខ្មែរទូទៅ ។ តាមពត៌មានពីភ្នំពេញថា ចាប់ពីការប្រើល្បិចបោកនេះមក ធាន-វុទ្ធីរកប្រាក់បាន៦១លានដុល្លារអាមេរិក ។ តាមពត៌មានមកទៀតថា មន្ត្រីសង្ឃថ្នាក់ខ្ពស់បានដឹងថា ធាន-វុទ្ធីនេះបានឃោសនាបោកបញ្ឆោតពិតមែន ប៉ុន្តែលោកមិនហ៊ានទៅហាមភ្លាមៗ ដោយមានអ្នកធំនៅពីក្រោយជួយការពារ ។ ឥឡូវនេះ ធាន-វុទ្ធីបានសង់វីឡាចំនួន២៨ ។ តើប្រាក់ដែលសល់ពីសង់វីឡានិងកសាងព្រះពុទ្ធរូប យកទៅចែកចាយឲ្យអ្នកណាខ្លះ ដើម្បីបិទមាត់កុំឲ្យនិយាយអំពីការបោកបញ្ឆោតរបស់គាត់ ។ គេកំពុងតាមដានមើលតទៅទៀត តើធាន-វុទ្ធីមានប្រពន្ធប៉ុន្មាន ហើយសង់វីឡាឲ្យប្រពន្ធឲ្យម្តាយនៅកន្លែងណាខ្លះ ព្រោះគេឃើញរូបថតប្រពន្ធរបស់គាត់ម្នាក់ ដែលស្លៀកសំលៀកបំពាក់ដ៏មានតម្លៃ។ ការបោកមួយទៀតជារបៀបធ្វើជំនួញ គឺឲ្យគេយកវត្ថុផ្សេងៗមកលក់ថាជាវត្ថុស័ក្តិសិទ្ធិ ដោយឲ្យកុំមីស្យុងអ្នកនាំយកមកលក់ ។

តើអ្នកជឿធាន-វុទ្ធីមានប្រយោជន៍អ្វី ក្រៅពីអស់ប្រាក់កាស ខ្លះអស់រាប់ម៉ឺនដុល្លារ ។ សកម្មភាពរបស់ធាន-វុទ្ធីមានកំហុសតាមផ្លូវរដ្ឋ ព្រោះធ្វើឲ្យខ្មែរជ្រួលច្របល់អស់ប្រាក់កាសនៅពេលដែលខ្មែរកំពុងតែក្រីក្រ ជារបៀបប្លន់ទ្រព្យសម្បត្តិជាប្រយោល ។ មានកំហុសតាមផ្លូវព្រះពុទ្ធសាសនា ព្រោះធ្វើឲ្យពុទ្ធសាសនិកជនខ្មែរយល់ខុស បែរគំនិតពីព្រះត្រៃបិដក អដ្ឋកថាដីកា ដែលជា

គោលរបស់ព្រះពុទ្ធសាសនា ចាត់ជាអ្នកបំផ្លាញព្រះពុទ្ធសាសនា ។ តទៅនេះជាអត្ថបទរបស់សារពត៌មាន «រាស្ត្រសច្ចៈ» ដែលចេញផ្សាយនៅថ្ងៃទី៧សីហា ២០០៩នៅទីក្រុងភ្នំពេញ អំពីរបៀបបោករបស់ផាន-វុទ្ធី ៖

## លឺថាផាន-វុទ្ធីនៅវត្តទូលរាជាក្លែងជាព្រះសិរអារមេត្រី និងឃោសនាបោកប្រាស់ពុទ្ធបរិស័ទ

ផាន-វុទ្ធី ជាឈ្មោះបុរសម្នាក់ដែលឈរឈ្មោះសាងសង់សមិទ្ធផលនានានៅក្នុងវត្តទូលរាជា ស្ថិតក្នុងភូមិកំពង់គរ ឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្តាល ជាមនុស្សខ្វាត់ព្រាត់ អនាថា មកពីស្រុកព្រៃកប្បាស ខេត្តតាកែវ ។ ផាន-វុទ្ធីចាប់ផ្តើមចេញចូលវត្តទូលរាជាក្នុងអំឡុងឆ្នាំ១៩៩៩ តែមិនបានស្នាក់នៅជាអចិន្ត្រៃយ៍នោះទេ ។ នៅចុងឆ្នាំ១៩៩៦ ក្នុងខែកក្កដា ផាន-វុទ្ធីបានស្គាល់លោកតាបួសស្លៀកសពាក់ស បែបលោកសង្ឃទ្រង់ព្រះភ្លូស ជនជាតិចិនព្រះនាម ចាន់ ហើយឆាន់ម្ហូបបួសនិងបងស្រី ចាន់-វុទ្ធី ព្រមទាំងភិក្ខុយុង-ផេងគង់វត្តបទុមវត្តី ហើយសុំឲ្យលោកតានិងបងស្រី ចាន់-វុទ្ធី ធ្វើបុណ្យផ្កានៅអាស្រមលោកតាចាន់ ស្ថិតក្នុងសង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ ពេលធ្វើបុណ្យផ្ការួច បច្ច័យដែលពុទ្ធបរិស័ទចូលចាប់មគ្គផលបានជាង២លានរៀល ហើយក៏ឲ្យផាន-វុទ្ធី ។ ពេលនោះផាន-វុទ្ធីក៏យកបច្ច័យទាំងជាង២លានរៀល នោះទិញព្រះពុទ្ធរូបតូចៗដែលធ្វើអំពីស្ពាន់ ហើយក្នុងព្រះពុទ្ធរូបនោះមានបង្កប់គ្រាប់កងតូចៗ ព្រះពុទ្ធរូបតូចៗទិញនៅក្នុងផ្សារទូលទំពូង ។ កាលនោះមួយព្រះអង្គតម្លៃ១២០០រៀលតែប៉ុណ្ណោះ ។ នយោបាយបោកប្រាស់របស់ផាន-វុទ្ធីគឺក្នុងឆ្នាំ១៩៩៧ គេយកព្រះពុទ្ធរូបតូចៗទៅដាក់ក្នុងបាត្ររួចទៅកប់ក្នុងដី បន្ទាប់មកឲ្យមេខ្យល់ដើរឃោសនាប្រាប់ពុទ្ធបរិស័ទថា នៅអាស្រមវត្តទូលរាជាមានព្រះផុស ។ ពេលពុទ្ធបរិស័ទដឹងហើយ ក៏នាំគ្នាភ្លូកទឹកភ្លូកដីមកគ្រប់ទិសទីគ្រប់ខេត្តក្រុង មកជាវព្រះពុទ្ធរូបផុស ដោយមួយអង្គជាវក្នុងតម្លៃ១៥,០០០រៀលឬស៊ីម៉ង់មួយបាវ ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ផាន-វុទ្ធីរកលុយបានរាប់រយលានរៀលរួចមកហើយ ។ ដល់ពេលពុទ្ធបរិស័ទជ្រាបរឿងពីកលល្បិចដ៏គំរក់របស់ខ្លួន ផាន-វុទ្ធីបានបាត់បង់ប្រជាប្រិយភាពយ៉ាងខ្លាំង ព្រោះអ្នកណា

ទៅដែលជឿនោះ ព្រះអង្គរីរីក៏ផុសច្រើនម៉្លេះ ទាំងបាតៗមិនចេះអស់ ។ ភ្លាមៗ នោះពុទ្ធបរិស័ទក្នុងស្រុកកោះធំក៏ដឹងពីគំនិតដ៏ពិសពុលបែបនេះ លែងមានជំនឿលើផាន-វុទ្ធី ហើយក៏បាននាំគ្នាធ្វើបាតុកម្មដុតទង់នឹងសម្ភារៈផ្សេងៗក្នុងវត្ត ដើម្បីបណ្ដេញផាន-វុទ្ធីចេញពីទូលរាជា ។ មានប្រជាពុទ្ធបរិស័ទខ្លះដែលមានស្រុកកំណើតជាមួយផាន-វុទ្ធី ពេលដែលពួកគាត់មកលក់ដូរទំនិញក្នុងស្រុកកោះធំបាននិយាយថា អាមេបោកនេះ (ផាន-វុទ្ធី) បោកគេឯងនៅស្រុកព្រៃកប្បាសអស់ចិត្តហើយ ឥឡូវនេះមកបោកគេនៅក្នុងស្រុកកោះធំទៀត ។

ដោយឡែក ផាន-វុទ្ធី ពេលដឹងថាប្រជាពុទ្ធបរិស័ទឈប់ជឿលើខ្លួនហើយ ក៏ខំប្រឌិតរឿងមួយទៀត គឺផាន-វុទ្ធីបានតាំងខ្លួនឯងថា ជាសម្ដេចជួន-ណាតចាប់ជាតិ ។ «រាស្ត្រសច្ចៈ»សួរថា តើសម្ដេចជួន-ណាតឯណាមកចាប់ជាតិកើតជាមនុស្សបែបផាន-វុទ្ធីនេះ ។ លក្ខណៈកាយសម្បទាមិនគ្រប់ គឺស្រឡេវស្រឡែកហើយវៀចមាត់ទៀត ហើយនិយាយធម៌មិនដឹងថា ជាធម៌មកពីឋានណា ។ សម្ដេចជួន-ណាតកាលពីព្រះអង្គនៅមានព្រះជន្មនៅឡើយ ព្រះអង្គខិតខំសាងសន្សំបុណ្យកុសលខ្លាំងណាស់ ។ ព្រះអង្គមានស្នាមព្រះហស្ដជាច្រើនដូចជា វចនានុក្រមខ្មែរ បទភ្លេងជាតិ (នគររាជ) និងអត្ថបទសៀវភៅធម៌ជាច្រើនទៀត ។ល។ និង ។ល។ ចុះហេតុអ្វីបានជាព្រះអង្គមានកម្មពៀរវេរាចាប់កំណើតជាមួយមនុស្សលោក បែរជាមានបុគ្គលិកលក្ខណៈមិនគ្រប់គ្រាន់ដូចផាន-វុទ្ធីនេះ ។ បើ«រាស្ត្រសច្ចៈ»វិភាគមើលទៅ កលល្បិចឃោសនាបោកបញ្ឆោតក៏កាន់តែសាបរលាបទៅហើយ ។ ស្រាប់តែថ្មីៗនេះ ផាន-វុទ្ធីក៏ប្រើមធ្យោបាយទេសនាថតតាមវីដេអូ វីស៊ីឌី ឌីវីឌី តាំងខ្លួនជាព្រះសេរអារ្យមេត្រីយ៍គង់លើផ្កាឈូក ហោះនៅពពក ដើម្បីបំភ័ន្តពុទ្ធបរិស័ទឲ្យជឿមកលើខ្លួនថា ពិតជាអ្នកមានបុណ្យមែន ។ តែធាតុពិត ផាន-វុទ្ធីនេះជាមនុស្សទមិឡអត់សាសនា ដែលមិនជឿកម្មផល កម្មពៀរវេរា ប្រើគ្រប់វិធីសាស្ត្រក្នុងការភូតភរពុទ្ធបរិស័ទ ទាំងក្នុងនិងក្រៅប្រទេស ដូចជាទី១- ទិញព្រះពុទ្ធរូបមកដាក់ក្នុងបាតហើយកប់ រួចថាផុស ។ ទី២- តាំងខ្លួនឯងថាជាសម្ដេចជួន-ណាតចាប់ជាតិ ។ ទី៣- តាំងខ្លួនឯងជាព្រះសេរអារ្យមេត្រីយ៍ ។ ទី៤- ប្លន់សមិទ្ធផលក្នុងវត្តទូលរាជា សុទ្ធតែមកពីឋានលើ ។ ទី៥- រាល់បុណ្យកឋិនទាន ស្បង់ត្រៃចីវរ គឺព្រះ

ឥន្ទបោះយកទៅក្រាលគ្រងនៅឯឋានលើ ។ ទី៦- ធាន-វុទ្ធីគឺប្រមាថមើលងាយព្រះសង្ឃទូទៅ ហើយនិងថ្នាក់ដឹកនាំព្រះសង្ឃមានសម្តេចព្រះសង្ឃរាជជាដើម ។ ទី៧- ធាន-វុទ្ធីឲ្យព្រះសង្ឃនិមន្តចេញចូលវត្តទូលរាជា ឬដូនជី យាយជី តាជី ឬក្រុមខ្យល់របស់ខ្លួនឲ្យជួយដើរឃោសនាធ្វើកឋិនទាន បុណ្យផ្កា ឬរៃអង្គាសគ្រប់មជ្ឈដ្ឋាន ខ្លួននឹងឲ្យភាគរយគឺកុំមីស្យុង ។ ឧទាហរណ៍ដូចមានព្រះសង្ឃមួយអង្គគង់នៅវត្តបទុមវត្តី (ភ្នំពេញ) ព្រះអង្គស្គាល់លោកជំទាវ ហើយទាក់ទងឲ្យជំទាវនោះធ្វើកឋិនទៅទូលរាជា លុះហែរកឋិនដល់ទូលរាជាហើយបានបច្ច័យចំនួន៨លានរៀល ពេលនោះធាន-វុទ្ធីបានដកបច្ច័យពាក់កណ្តាលគឺចំនួន៤លានរៀល ប្រគេនទៅព្រះសង្ឃដែលខំទាក់ទងលោកជំទាវ ដែលហែរកឋិនចូលវត្តទូលរាជា ។

បើគំនិតរកស៊ីបែបធាន-វុទ្ធីនេះ តើពេលបុណ្យម្តងៗត្រូវចំណាយប៉ុន្មានសំរាប់ឲ្យថ្លៃកុំមីស្យុងនោះ បើកឋិនម្តងៗអ្នកហែរចូលរាប់រយត្រៃចីវរគ្រប់ទិសទី ។ ហើយបើនិយាយពីត្រៃចីវរទាំងនោះវិញ គឺគ្មានព្រះឥន្ទព្រះព្រហ្មឯណាយកទៅក្រាលគ្រងនៅឋានលើឯណាទេ គឺព្រះសង្ឃ ឬដូនជី តាជី ដែលដង្ហែកឋិនទៅនឹងឯង ដែលយកមកភ្នំពេញវិញ ហើយយកទៅលក់នៅភ្នំពេញ ។ ប្រការនេះហើយដែលធាន-វុទ្ធីចេះតែលោតឡើងៗមិនខ្លាចធ្លាក់បាក់ក ព្រោះពេលកឋិនទានហើយម្តងៗ ធាន-វុទ្ធីប្រមូលលុយបានពី៥បាវទៅ១៥បាវ នេះយើងមិនបាច់និយាយថារាប់លានទេ ។ សួរថាចុះប្រជាពុទ្ធបរិស័ទនៅក្នុងស្រុកកោះធំ គ្មានអ្នកណាម្នាក់ជឿធាន-វុទ្ធីទេ គឺក្រៅពីអ្នកដែលធាន-វុទ្ធីផ្តល់លាភសក្ការៈឲ្យរៀងរាល់ថ្ងៃនោះហើយ មានខ្លះទៀតឲ្យប្រចាំខែ រហូតដល់មានពាក្យខ្សឹបខ្សៀវគ្នាថា ធាន-វុទ្ធីមានខ្នងធំៗជួយកាងពីក្រោយ ហើយយកលុយបច្ច័យរបស់សប្បុរសជន ប្រមូលបានពីបុណ្យទៅប្រើប្រាស់ផ្ទាល់ខ្លួន ។

កត្តាទាំងនេះហើយបានជាថ្មីៗនេះ ធាន-វុទ្ធីជិះសេះលែងដៃ ធ្វើព្យុះធ្វើផ្គរខ្យល់យ៉ាងណាក៏គ្មានស្ថាប័នណាមួយចេញមុខដោះស្រាយឡើយ ។ ពីមុនធានវុទ្ធីស្រាប់តែអង្គុយខាងលើព្រះសង្ឃ (អង្គុយដើមទី) ហើយផ្តើមសូត្រធម៌ ចំណែកព្រះសង្ឃសូត្រតាមក្រោយ តែឥឡូវនេះមានគេនិយាយថា ធាន-វុទ្ធីហ៊ានបំបួសលោកសង្ឃ ហើយឲ្យព្រះសង្ឃថ្វាយបង្គំខ្លួន ព្រោះយល់ថាខ្លួនជា

ព្រះសេរអាមេត្រីយ៍ អង្គុយលើផ្កាឈូកហោះលើពពក ហើយស្លៀកសពាក់សប្លងសក់ឡើង តែតាមការពិត ផាន-វុទ្ធីពេលនៅក្រៅវត្តទូលរាជា គឺស្លៀកពាក់ស៊ីវិលសក់មិនដែលកោរ លុះទៅដល់វត្តចុះពីឡាន ទើបចូលទៅប្តូរស្លៀកពាក់ស។ «រាស្ត្រសច្ចៈ»សួរមនុស្សបែបផាន-វុទ្ធីនេះ យើងគួរជឿហើយគោរពថ្វាយបង្គំដែរឬទេ ? តើយើងរកលុយបានដោយពិបាកណាស់ ហេតុអ្វីបានជាយកទៅឲ្យផាន-វុទ្ធីទិញដី សង់ផ្ទះ សំរាប់បំពេញមហិច្ឆិតារបស់ខ្លួនទៅវិញ ។ ផាន-វុទ្ធីសល់លុយច្រើនណាស់ សង់ផ្ទះឲ្យម្តាយខ្លួន ហើយផ្ទះសំរាប់ខ្លួនឯងទៀត ហើយឥឡូវសង់វីឡាភូមិគ្រឹះដាក់ឈ្មោះថាបុរីរាជានៅក្នុងវត្តចំនួនដល់ ២៨វីឡា សំរាប់ទុកឲ្យមន្ត្រីអ្នកធំដែលជាខ្នងរបស់ខ្លួនសម្រាក និងសម្រាប់ពួកមេខ្យល់ដែលស៊ីភាគរយ ដែលមកពីបរទេសមកស្នាក់នៅជំនួសសណ្ឋាគារ ។

«រាស្ត្រសច្ចៈ»សូមសំណូមពរដល់ក្រសួងសម្តេចព្រះសង្ឃរាជ និងក្រសួងធម្មការ ព្រមទាំងស្ថាប័នពាក់ព័ន្ធ លោកមេត្តាជួយស្រាវជ្រាវរកមូលហេតុដែលផាន-វុទ្ធីបង្កើតជាមង្គលភ្ញាក់ផ្អើល និងយកព្រះពុទ្ធសាសនាធ្វើជាអាជីពដើរបោកប្រាស់ពុទ្ធបរិស័ទពាសពេញពិភពលោក ដើម្បីទប់ស្កាត់និងកាត់បន្តយភាពក្រីក្ររបស់ពុទ្ធបរិស័ទ ព្រមទាំងលើកកំពស់សេដ្ឋកិច្ចសង្គមជាតិ ក៏ដូចជាគ្រួសារឲ្យបានល្អប្រសើរឡើងវិញ ។ «រាស្ត្រសច្ចៈ»ក៏សុំផ្តាំផ្ញើដល់ពុទ្ធសាសនិកជនទាំងក្នុងក្រៅប្រទេស មេត្តាយកបញ្ហាមកពិចារណារកហេតុផលឲ្យបានច្បាស់លាស់ មុននឹងជឿរឿងអ្វីមួយ ហើយល្អបំផុតនោះ គឺយកលុយកាក់នោះទុកចិញ្ចឹមឪពុកម្តាយដែលជាព្រះពិត ជាព្រះព្រហ្ម និងជាព្រះអរហន្ត ឬក៏ចិញ្ចឹមកូនចៅឱ្យបត្តម្ភរៀនសូត្រឲ្យបានខ្ពង់ខ្ពស់ ទទួលបានសញ្ញាប័ត្រខ្ពស់ ជាគុណាប្រយោជន៍ជួយកសាងប្រទេសជាតិខ្មែរ ឲ្យស្គាល់ភាពសំបូរសប្បាយរុងរឿងដូចអរិយប្រទេសវិញប្រសើរជាង ។

សារពត៍មាន«រាស្ត្រសច្ចៈ» មិនអាចសុំការទំនាក់ទំនងពីលោកផាន-វុទ្ធីបានឡើយ ។៚

❄ ❄

❄